# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៥៩

នាសប្តាហ៍នេះ  អង្គជំនុំជម្រះសាលាដំបូងបានទទួលជោគជ័យក្នុងការបិទបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សីចំនួនពីររូប និងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ក្នុងផ្នែកជំនុំជម្រះលើសំណុំរឿង០០២ វគ្គ២ ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង។ មានបុគ្គលចំនួនបីនាក់ ត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម ស្តីពីមន្ទីរសន្តិសុខភ្នំក្រោល ក៏ប៉ុន្តែ ពួកគេក៏បានផ្តល់ភស្តុតាងពាក់ព័ន្ធនឹងបញ្ហាផ្សេងៗទៀតជាច្រើនផងដែរ។ សាក្សីទីមួយ លោក **ប៊ិន ឡឹងចូយ** បានផ្តល់សក្ខីកម្មស្តីពីតួនាទីរបស់គាត់ជាយុទ្ធជនក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបានពិភាក្សាអំពីជោគវាសនារបស់សាច់ញាតិរបស់គាត់ ដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខភ្នំក្រោលផងដែរ។ សាក្សីបន្ទាប់ លោក **សៅ សារុន** ដែលជាអតីតលេខាតំបន់១០៥ ក្នុងខេត្តមណ្ឌលគីរី បានផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ សាក្សីលោក **សៅ សារុន** ក៏ធ្លាប់បានផ្តល់សក្ខីកម្មរួចមកហើយកាលពីពេលមុនក្នុងសំណុំរឿង០០២ វគ្គ១ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខអូរកន្សែងនេះផងដែរ។[1] ជាទីចុងបញ្ចប់នាសប្តាហ៍នេះ ដើមបណ្តឹងរដ្ឋប្បវេណីលោក **សុន វុធ** បានផ្តល់សក្ខីកម្មស្តីពីការឃុំខ្លួនរបស់គាត់នៅមន្ទីរសន្តិសុខភ្នំក្រោល និងការបាត់បង់ឪពុកម្តាយ បងប្អូនបង្កើត និងសាច់ញាតិដទៃទៀតរបស់គាត់ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

---

[1] សាក្សីលោក **សៅ សារុន** ធ្លាប់បានផ្តល់សក្ខីកម្មកាលពីពេលមុនក្នុងសំណុំរឿង០០២ វគ្គ១ សម្រាប់សេចក្តីសង្ខេបស្តីពីសក្ខីកម្មរបស់គាត់កាលពីពេលមុននោះ *សូមមើល* របាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម លេខ២៦ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី២១ (ចុះថ្ងៃទី១១ ដល់ទី១៤ ខែមិថុនា ឆ្នាំ២០១២) ទំព័រ ១ដល់៤។

[*] របាយការណ៍នេះ ត្រូវបានសរសេរដោយ ហេង ស៊ីនវុត្ថា, ម៉ាលេនី ហៃដ៍ (Melanie Hyde), នីកូឡាស មេយខក (Nicholas Maycock), ខេតលីន កាហ្វព្រៀ (Caitlin McCaffrie), នំ វិសុទ្ធ និង តាយ លីណា ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូលូលូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (THE WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University